**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

JS LAND PLC

**ក្រុមហ៊ុន ជេអេស ឡែន ភីអិលស៊ី**
លេខ: ២០២៥/០០៥/ជ.អ.ល.ក ជ.អ.ល.

# សេចក្តីជូនដំណឹង
# ស្តីពី
# វិសោធនកម្មលក្ខន្តិកៈរបស់ក្រុមហ៊ុន ជេអេស ឡែន ភីអិលស៊ី

**ក្រុមហ៊ុន ជេអេស ឡែន ភីអិលស៊ី** (ជ.អ.ល.) មានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូន វិនិយោគិន និងសាធារណជនទាំងឡាយ មេត្តាជ្រាបថា **ក្រុមហ៊ុន ជេអេស ឡែន ភីអិលស៊ី** បានទទួលសេចក្តីសម្រេចយល់ព្រមលើការស្នើសុំធ្វើវិសោធនកម្មលក្ខន្តិកៈក្រុមហ៊ុន ពីក្រសួងពាណិជ្ជកម្ម កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥។ ព័ត៌មានលម្អិតនៃវិសោធនកម្មមានដូចខាងក្រោម៖

I. ការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន

ក. មុនពេលផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល ៖

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទចាប់ផ្តើមអាណត្តិ | កាលបរិច្ឆេទបញ្ចប់អាណត្តិ |
|---|---|---|---|---|
| ១ | ឧកញ៉ា គួយ ឡេសាន | ប្រធានក្រុមប្រឹក្សាភិបាល | ២៦ តុលា ២០២១ | ២៥ តុលា ២០២៦ |
| ២ | លោក Dato' Yap Ting Chiat | អភិបាលប្រតិបត្តិ | ២៦ តុលា ២០២១ | ២៥ តុលា ២០២៦ |
| ៣ | ឧកញ៉ា ម៉េង លី | អភិបាលមិនប្រតិបត្តិ | ២៦ តុលា ២០២៤ | ២៥ តុលា ២០២៧ |
| ៤ | លោក Tang Chun Kiu | អភិបាលមិនប្រតិបត្តិ | ២៦ តុលា ២០២៤ | ២៥ តុលា ២០២៧ |
| ៥ | លោក Yap Maow Jun | អភិបាលមិនប្រតិបត្តិ | ០៦ កញ្ញា ២០២៥ | ០៥ កញ្ញា ២០២៨ |
| ៦ | លោក Yap Teng Wui | អភិបាលមិនប្រតិបត្តិ | ០៦ កញ្ញា ២០២៥ | ០៥ កញ្ញា ២០២៨ |
| ៧ | លោក Tang Chat Tong | អភិបាលមិនប្រតិបត្តិ | ០៦ តុលា ២០២២ | ០៥ កញ្ញា ២០២៥ |
| ៨ | លោក តាន់ សៃឆាយ | អភិបាលឯករាជ្យ | ២៦ តុលា ២០២១ | ២៥ តុលា ២០២៤ |
| ៩ | លោក Dato' Tan Teck Zin | អភិបាលឯករាជ្យ | ០៦ កញ្ញា ២០២៥ | ០៥ កញ្ញា ២០២៨ |

ខ. ក្រោយពេលផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល ៖

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទចាប់ផ្តើមអាណត្តិ | កាលបរិច្ឆេទបញ្ចប់អាណត្តិ |
|---|---|---|---|---|
| ១ | ឧកញ៉ា គួយ ឡេសាន | ប្រធានក្រុមប្រឹក្សាភិបាល | ២៦ តុលា ២០២១ | ២៥ តុលា ២០២៦ |
| ២ | លោក Dato' Yap Ting Chiat | អភិបាលប្រតិបត្តិ | ២៦ តុលា ២០២១ | ២៥ តុលា ២០២៦ |
| ៣ | ឧកញ៉ា ម៉េង លី | អភិបាលមិនប្រតិបត្តិ | ២៦ តុលា ២០២៤ | ២៥ តុលា ២០២៧ |
| ៤ | លោក Tang Chun Kiu | អភិបាលមិនប្រតិបត្តិ | ២៦ តុលា ២០២៤ | ២៥ តុលា ២០២៧ |
| ៥ | លោក Yap Maow Jun | អភិបាលមិនប្រតិបត្តិ | ០៦ កញ្ញា ២០២៥ | ០៥ កញ្ញា ២០២៨ |
| ៦ | លោក Yap Teng Wui | អភិបាលមិនប្រតិបត្តិ | ០៦ កញ្ញា ២០២៥ | ០៥ កញ្ញា ២០២៨ |
| ៧ | លោក Dato' Tan Teck Zin | អភិបាលឯករាជ្យ | ០៦ កញ្ញា ២០២៥ | ០៥ កញ្ញា ២០២៨ |

## II. ការកែប្រែខ្លឹមសារលើមាត្រា ១៧.៥ ៖

| មុនពេលវិសោធនកម្ម | ក្រោយពេលវិសោធនកម្ម |
|---|---|
| ពី៖ សេចក្តីសម្រេចទាំងអស់របស់ក្រុមប្រឹក្សា ត្រូវតែទទួលបានការអនុម័តដោយសំឡេងភាគច្រើនទូទៅរបស់អភិបាល ដែលមានវត្តមានដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលណាមួយ លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងលក្ខន្តិកៈនេះ។ គ្មានសេចក្តីសម្រេចណាមួយ ត្រូវភ្ជាប់កាតព្វកិច្ចលើក្រុមហ៊ុនបានឡើយ ប្រសិនបើមិនត្រូវបានអនុម័តតាមរបៀបនេះទេ។ អភិបាលម្នាក់ៗបូករួមទាំងប្រធានក្រុមប្រឹក្សាភិបាល ឬអ្នកតំណាង មានមួយសំឡេងក្នុងការបោះឆ្នោត។ | ទៅជា៖ (រក្សាទុកកថាខណ្ឌដែលមានស្រាប់នៅដដែល) បន្ថែមកថាខណ្ឌថ្មី ដែលមានខ្លឹមសារដូចខាងក្រោម៖<br><br>បន្ទាប់ពីសេចក្តីសម្រេច ត្រូវបានទទួលការអនុម័តយល់ព្រមត្រឹមត្រូវដោយក្រុមប្រឹក្សាភិបាល ដោយអនុលោមតាមកថាខណ្ឌខាងលើរួចរាល់ ក្រុមហ៊ុនអាចចេញកំណត់ត្រាជាលាយលក្ខណ៍អក្សរ នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ដែលទទួលបានការអនុម័តសម្រេចនេះ ហើយកំណត់ត្រាជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ដែលទទួលបានការអនុម័តសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និង លេខាធិការក្រុមហ៊ុន។ |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៥ កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥
**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**

ចុះបញ្ជីក្រោមលេខ
Registration No. 00010332

លេខ B២-១០៧ អគារ The Elysee កោះពេជ្រ វិថីកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#B2-107, The Elysee Diamond Island, Koh Pich Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 010 88 66 99
E-mail: info@jslandplc.com, Website: www.jslandplc.com